ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



15-7-09

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០៧ សហវ
15/7/09

# សារាចរណែនាំ
## ស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគំរោងថវិកា
## រាជធានី ខេត្ត ឆ្នាំ ២០១០

យោងសារាចរណែនាំលេខ ០៩ សរណន ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០១០ ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំស្តីពីនីតិវិធីបច្ចេកទេស នៃការរៀបចំគំរោងថវិការាជធានី ខេត្ត ឆ្នាំ២០១០ ដូចខាងក្រោម ÷

## I. ការរៀបចំចំណូលថវិកា :

1. ចំណូលចរន្តរបស់ថវិការាជធានី ខេត្ត ត្រូវបានគិតគូរលើមូលដ្ឋានប្រភពចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ ដែលបានកំណត់ដោយច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ត្រូវរៀបចំនូវគំរោងចំណូលថវិកានេះ ដូចតទៅ ÷

- ចំណូលសារពើពន្ធ ត្រូវគិតគូរដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម ÷
  + លទ្ធផលដែលទទួលបាននៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ
  + ផលប៉ះពាល់នៃអតិផរណាមកលើមូលដ្ឋានពន្ធ
  + ប៉ាន់ស្មានលើការរីកចំរើនសេដ្ឋកិច្ចនៅពេលខាងមុខ
  + ការប្រែប្រួលដែលអាចកើតមានឡើងដោយអត្រា និងចំនួនមូលដ្ឋានប្រមូលពន្ធ
  + ចំណូលដែលសង្ឃឹមថា បានមកពីការបង្កើតពន្ធថ្មី (ករណីមានគោលនយោបាយថ្មី) ។

- ទន្ទឹមនឹងនេះ ចំណូលមិនមែនសារពើពន្ធ ត្រូវបានគិតគូរទៅតាមកិច្ចការដែលនាំអោយមានផលទុន ដូចជាកិច្ចសន្យាជួល សេវាកម្ម និងកែលំអគារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋព្រមទាំងប្រមូលបំណុលដែលត្រូវទារជាដើម ។ ចំណូលទាំងអស់នេះ ត្រូវផ្អែកលើមូលដ្ឋានតួលេខស្ថិតិសំរេចបាននៃឆ្នាំកន្លងមក និងការរីកចំរើននៃសេដ្ឋកិច្ច ។

ចំពោះនីតិវិធី គឺអភិបាលរាជធានី ខេត្ត ត្រូវអញ្ជើញមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សាខាពន្ធដារ និងមន្ទីរជំនាញ ដែលពាក់ព័ន្ធក្នុងការប្រមូលចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ សំរាប់ថវិការាជធានី ខេត្ត ដើម្បីមក

ចូលរួមពិភាក្សាគិតគូររៀបចំជាគំរោងចំណូលទៅតាមជំពូក គណនី អនុគណនីនៃតារាងឧបសម្ព័ន្ធទី ១ ដែលជូនភ្ជាប់មកជាមួយនេះ ។

2. ចំណូលផ្ទៃក្នុងជាមូលធនរបស់ថវិការាជធានី ខេត្ត ក្នុងករណីដែលមានគឺ ត្រូវយកចិត្តទុកដាក់បញ្ចូលទៅក្នុងគំរោងចំណូល ។ ទន្ទឹមនឹងនេះក៏ត្រូវយកចិត្តទុកដាក់កត់ត្រាបញ្ចូលនូវចំណូលពីជំនួយមនុស្សធម៌ និងជំនួយពីបរទេសដែលសប្បុរសជន អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលនានា បានទៅទំនាក់ទំនងផ្តល់ហិរញ្ញប្បទានផ្ទាល់ជាមួយរាជធានី ខេត្ត រួចហើយនោះ។

## II. ការរៀបចំចំណាយថវិកា :

3. រាជធានី ខេត្ត ត្រូវរៀបចំនូវគំរោងចំណាយទៅតាមជំពូក គណនី អនុគណនី សំរាប់រាល់សកម្មភាពសេវាទាំងអស់ ដោយកាត់បន្ថយមុខចំណាយណាដែលពុំចាំបាច់ ដែលស្ថិតនៅក្រោមឱវាទរបស់ខ្លួន ។ របៀបគិតគូរនូវតំរូវការនានា គឺជាការកំណត់នូវមុខចំណាយនីមួយៗអោយច្បាស់លាស់ និងដោយផ្អែកទៅលើកត្តានានា ដែលទាក់ទងផ្ទាល់ទៅនឹងមុខចំណាយនោះដូចជា តារាងបុគ្គលិក បញ្ជីប៉ាន់ស្មានបរិមាណ តំលៃ សម្ភារៈ ឬសេវា..។ ចំពោះសម្ភារៈបរិក្ខា ដែលប្រើប្រាស់ជាប្រចាំត្រូវគិតគូរដោយផ្អែក តាមតួលេខស្ថិតិគណនេយ្យថវិកាជាមធ្យមភាគ នៃបណ្តាឆ្នាំកន្លងមក ។ ចំណែកសោហ៊ុយធ្វើដំណើរ ស្នាក់នៅ បេសកកម្ម ត្រូវផ្អែកលើរបបកំណត់ជាធរមាន (អនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០៤ ស្តីពីការកំណត់ប្រាក់របបបេសកកម្មក្នុង និងក្រៅប្រទេស) ។

គំរោងចំណាយទាំងអស់របស់ថវិការាជធានី ខេត្តត្រូវបានសរុបនៅក្នុងតារាងឧបសម្ព័ន្ធទី ២ "ក" និង"ខ" ដែលជូនភ្ជាប់មកជាមួយនេះ។

4. ជាទូទៅ សំណើចំណាយទាំងអស់ត្រូវតែមានការវិភាគ និងមានលិខិតយុត្តិការភ្ជាប់មកជាមួយតាមជំពូក គណនី អនុគណនី ដើម្បីបង្ហាញអោយឃើញថាការគិតគូរចំណាយរបស់ខ្លួនមានភាពត្រឹមត្រូវ ហ្មត់ចត់ និងសមហេតុផល ។ លិខិតយុត្តិការទាំងអស់នេះ នឹងធ្វើជាមូលដ្ឋាននៃការពិនិត្យពិភាក្សាថវិកា ។

### II.1. ការរៀបចំគំរោងចំណាយចរន្ត :

5. លិខិតយុត្តិការនៃចំណាយចរន្តមានគោលដៅសំខាន់ៗដូចតទៅ ÷

**ប្រភេទ ១ : មធ្យោបាយសេវា**

**ជំពូក ៦២ និង ៦៤ សេវាខាងក្រៅផ្សេងៗ និងបន្ទុកបុគ្គលិក**

6. ចំណាយសំរាប់បុគ្គលិកត្រូវតែគិតគូរអោយបានច្បាស់លាស់ ។ ចំណាយលើជំពូក ៦៤ ត្រូវបានចាត់ទុកជា

ចំណាយដែលមានអាទិភាពបំផុតក្នុងការរៀបចំគំរោងថវិកា ។ ចំណាយបន្ទុកបុគ្គលិកត្រូវគ្រោងដោយបង្កើន២០% លើបៀវត្សមូលដ្ឋាននៃតារាងប្រាក់បៀវត្សដែលចេញដោយក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលសាធារណៈនិងតាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងក្នុងឆ្នាំ ២០០៩ ។ ចំពោះចំនួនមន្ត្រីរាជការបន្ថែមថ្មី ត្រូវគ្រោងដោយផ្អែកលើសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងដែលមានទិដ្ឋាការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬ លាឈប់ពីក្របខ័ណ្ឌរដ្ឋ និងមរណៈភាព ត្រូវកាត់ចេញពីអង្គភាពរបស់ខ្លួន ។ ប្រសិនបើមានការតម្លើងឋានៈ ឬ មានមន្ត្រីថ្មី ត្រូវគ្រោងដោយឡែក ។ រាជធានី ខេត្ត មិនត្រូវគិតអតិផរណានៅក្នុងចំណាយបៀវត្សនេះទេ ។

ចំពោះគំរោងចំណាយអំពីប្រាក់បំណាច់បុគ្គលិកអណ្តែត គំរោងចំណាយអំពីលាភការភ្ជាក់ងារជាប់កិច្ចសន្យា និងកន្ទោមអាទិភាព គឺចាំបាច់ត្រូវតែមានសេចក្តីសំរេចអនុញ្ញាតពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងក្របខ័ណ្ឌឥណទាន ដែលបានពិភាក្សារួចហើយជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ដោយឡែកប្រាក់ឧបត្ថម្ភប្រចាំខែរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រោងនៅក្នុងជំពូក ៦៤ គណនី ៦៤៤ អនុគណនី ៦៤៤២ ។

ក្នុងករណីដែលរាជធានី ខេត្ត មានតម្រូវការអំពីបុគ្គលិកអណ្តែត ភ្នាក់ងារជាប់កិច្ចសន្យាសំរាប់ការងារឯកទេសដែលត្រូវចុះកិច្ចសន្យាអនុវត្តសំរាប់រយៈពេលខ្លីជាកំណត់គឺត្រូវគ្រោងនៅក្នុងជំពូក ៦២ ។

7. ចំនួនបុគ្គលិកទាំងអស់ ដែលស្ថិតនៅក្រោមឱវាទរាជធានី ខេត្ត ត្រូវបូកសរុបនៅក្នុងតារាង៥ "ក" និងចំនួនក្រុមប្រឹក្សាទាំងអស់ត្រូវបូកសរុបនៅក្នុងតារាង ៥ "ខ" ដែលបានភ្ជាប់ជូនមកជាមួយនេះ ។ សលាកប័ត្រនេះមានចែកជាច្រើនខ្ទង់ សំរាប់កត់ត្រានូវប្រភេទបុគ្គលិកទាំងអស់ដែលរាជធានី ខេត្ត មាន ។

8. បុគ្គលិក មន្ត្រីរាជការ ដែលលំអិតទៅតាមអង្គភាពនីមួយៗហើយចំនួន នេះត្រូវតែផ្ទៀងផ្ទាត់ជាមួយ នឹងចំនួនដែលមាននៅក្នុងតារាងសរុបចំណាយ (តាមតារាងប្រព័ន្ធប្រាក់បៀវត្សរបស់ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលសាធារណៈ) ។

9. រាជធានី ខេត្តត្រូវលំអិតចំនួនបុគ្គលិកទៅតាមក្រុង ស្រុក ខណ្ឌ នីមួយៗដែលស្ថិតនៅក្រោមឱវាទរបស់ខ្លួន។

## ជំពូក ៦០ និង ៦១ ការទិញ និងសេវាខាងក្រៅ

10. ជំពូក ៦០ និង ៦១ ប្រមូលផ្តុំរាល់ចំណាយដំណើរការរដ្ឋបាល ទិញសម្ភារៈ ជួសជុលតូច និងចំណាយជាគុណប្រយោជន៍របស់រាជធានី ខេត្ត ។ ឥណទានចំណាយក្នុងជំពូកនេះ ចែកចេញជាពីរផ្នែកសំខាន់ៗ ÷

មួយផ្នែកជាឥណទានសំរាប់បំរើអោយកិច្ចប្រតិបត្តិការរដ្ឋបាលសុទ្ធសាធ ដែលចាំបាច់ត្រូវគិតគូរអោយបានហ្មត់ចត់ និងសន្សំសំចៃដោយផ្អែកលើគោលការណ៍រួមរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងចំណាយសាធារណៈ ។ ក្នុងឆ្នាំ ២០១០ ឥណទានចំណាយផ្នែកនេះ គឺអនុញ្ញាតអោយគ្រោងក្នុងកំរិតប្រហាក់ប្រហែលនឹងឆ្នាំ២០០៩ តែប៉ុណ្ណោះ ។ ដោយឡែកថ្លៃឈ្នួលនិងបន្ទុក (គណនី ៦១៣) គឺអនុញ្ញាតអោយគ្រោងតែចំណាយសំរាប់ជួលស្នាក់ការរដ្ឋបាលតែប៉ុណ្ណោះ ។

មួយផ្នែកទៀតជាឥណទានសំរាប់បំរើដល់គុណប្រយោជន៍របស់រាជធានី ខេត្ត ក្នុងការរៀបចំមូលដ្ឋាន

ក្រសួងមហាផ្ទៃ រាជធានី ខេត្ត នីមួយៗចាំបាច់ត្រូវរៀបចំទៅតាមលំដាប់លំដោយនៃអាទិភាពរបស់គំរោង ចំណាយនីមួយៗ អំពីការងារជាគុណប្រយោជន៍របស់រាជធានី ខេត្ត ដើម្បីដាក់គំរោងនេះឆ្លងការពិភាក្សាជាមួយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងមហាផ្ទៃក្នុងពេលធ្វើការពិភាក្សាគំរោងថវិកាប្រចាំឆ្នាំ ។ ទន្ទឹមនោះ រាជធានី ខេត្ត ត្រូវយកចិត្តទុកដាក់បង្កើននូវចំណាយផ្នែកនេះ ក្នុងករណីដែលលទ្ធភាពចំណូលសំរេចបានលើសផែនការព្រោះការអភិវឌ្ឍន៍រាជធានី ខេត្ត គឺជាគោលបំណងនៃគោលនយោបាយ និងជាទិសដៅយុទ្ធសាស្ត្រអាទិភាពខ្ពស់បំផុតរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

11. អភិបាលរាជធានី ខេត្ត ត្រូវគ្រោងឥណទានសំរាប់ចំណាយជាគុណប្រយោជន៍រាជធានី ខេត្ត តាមការងារនីមួយៗ (បំភ្លឺសាធារណៈ ប្រមូលសំរាម អនាម័យ សន្តិសុខ ប្រឆាំងអគ្គីភ័យ ការផ្គត់ផ្គង់ទឹក...) និងតាមការដ្ឋាននីមួយៗ (ផ្លូវថ្នល់ ស្ពាន សួនច្បារ លូទឹក ប្រឡាយ...) ដោយមានបញ្ជាក់អំពីបញ្ជីប៉ាន់តម្លៃ និងទីតាំង ច្បាស់លាស់ដែលជាឯកសារសំរាប់ការពិភាក្សាថវិកាប្រចាំឆ្នាំ ។ ដោយឡែក ចំពោះសំណង់ថ្មីទាំងស្រុងត្រូវលើក គំរោង និងចុះទៅតាមគណនី និងអនុគណនី ត្រង់ជំពូក ២០ ( បើជាអចលកម្មអរូបីយ ) និងត្រង់ជំពូក ២១ (បើជា អចលកម្មរូបីយ ) ។

12. ជាទូទៅ ចំណាយដំណើរការរដ្ឋបាល ទិញសម្ភារៈ ការថែទាំ និងការជួសជុលតូច ត្រូវគិតគូរទៅតាមតំរូវការនៃកម្មវិធីសកម្មភាព ឬទៅតាមបទដ្ឋានសមស្រប។ ម្យ៉ាងទៀតរាជធានី ខេត្តមិនត្រូវបំប៉ោងឥណទានដែលស្នើសុំសំរាប់ចំណាយប្រភេទនេះទេ។ ឥណទានសំរាប់ចំណាយអចិន្ត្រៃយ៍ដូចជា ទូរស័ព្ទ អគ្គិសនី ទឹក សម្ភារៈការិយាល័យ ប្រេងឥន្ទនៈ ត្រូវកំណត់អោយបានត្រឹមត្រូវនិង គ្រប់គ្រងយ៉ាងម៉ឺងម៉ាត់ ដើម្បីសន្សំសំចៃលើចំណាយប្រភេទនេះជាពិសេសឥណទានសំរាប់ចំណាយទូរស័ព្ទ អគ្គិសនី ទឹក។ រាជធានី ខេត្ត ត្រូវគ្រោងអោយបានគ្រប់គ្រាន់សំរាប់តំរូវការក្នុងឆ្នាំ និងការសងបំណុល ។ ក្នុងករណីដែលរាជធានី ខេត្ត គ្រោងមិនបានគ្រប់គ្រាន់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងធ្វើនិយ័តភាពឥណទានផ្ទៃក្នុងជំពូកថវិការបស់រាជធានី ខេត្ត ហើយដាក់កម្មវិធីចំណាយសំរាប់ទូទាត់ជូនរាជធានី ខេត្ត ដោយស្វ័យប្រវត្តិ ។

## ប្រភេទ ៣ : ចំណាយអន្តរាគមន៍សាធារណៈ

## ជំពូក៦៥ : ការឧបត្ថម្ភធន និងជំនួយសង្គម

13. ចំណាយប្រភេទនេះ ត្រូវចែងលំអិតអោយបានច្បាស់លាស់ នូវគោលដៅដែលត្រូវសំរេច ។ ត្រូវពិនិត្យជ្រើសរើសចំណាយប្រភេទនេះអោយបានហ្មត់ចត់ ដោយផ្អែកលើលក្ខណៈសម្បត្តិនៃអ្នកដែលទទួលផលនិងចំនួនទឹកប្រាក់ដែលត្រូវពិនិត្យផ្តល់ជូន ។

## ប្រភេទ ៤ : ចំណាយផ្សេងៗ

## ជំពូក ៦៣ : ពន្ធ និងអាករ

14. ចំណាយប្រភេទនេះ គឺសំរាប់កាតព្វកិច្ចពន្ធ អាករ (លតាប័ត្រ.....) និងចំណាយផ្សេងៗ ទៀតតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ប្រភេទ ៦ : ចំណាយមិនបានគ្រោងទុក

## ជំពូក ០៩ : ចំណាយមិនបានគ្រោងទុក

15. ចំណាយប្រភេទនេះ គឺជាការគិតគូរគ្រោងបំរុងសំរាប់ចំណាយផ្សេងៗ ដែលអាចកើតមានជាយថាហេតុ នៅក្នុងឆ្នាំអនុវត្ត។ សំរាប់ឆ្នាំថវិកា ២០១០ ប្រភេទឥណទាន គឺអនុញ្ញាតអោយគ្រោងចំនួន ៣ ទៅ ៥ ភាគរយ ហើយខ្ទង់ចំណាយនេះ ពេលអនុវត្តត្រូវស្នើសុំផ្ទេរនិយ័តភាពទៅបំពេញអោយជំពូកដទៃទៀត ដែលតំរូវការចំណាយផ្សេងៗកើតមានឡើងជាយថាហេតុ ។

## II.2. ចំណាយជាមូលធន :

### ប្រភេទ ១ : អចលកម្ម

16. ចំណាយជាមូលធន គឺជាចំណាយសំរាប់ធ្វើហិរញ្ញប្បទានចំពោះគំរោងវិនិយោគ ដែលមានការព្រមព្រៀងគ្នាជាមុន និងសំដៅធ្វើអោយសំរេចតាមគោលដៅដែលបានដាក់ចេញ ។

17. គំរោងវិនិយោគរបស់រាជធានី ខេត្ត ដែលអាចគ្រោងបានក្នុងករណីដែលរាជធានី ខេត្ត បានទទួលគោលការណ៍ អនុញ្ញាតជាផ្លូវការអោយគ្រប់គ្រងហិរញ្ញប្បទានដោយផ្ទាល់ ។

- ការវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេសដោយថវិការាជធានី ខេត្ត អាចគ្រោងបានក្នុងករណីដែលរាជធានី ខេត្ត មានអតិរេកចរន្ត ឬ មានចំណូលជាមូលធនផ្ទៃក្នុងរាជធានី ខេត្ត ផ្ទាល់ ។

- ការវិនិយោគដោយហិរញ្ញប្បទានពីបរទេសផ្ទាល់ ត្រូវផ្អែកលើកម្មវិធីជំនួយ ឬគំរោងការដែលអង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ឬម្ចាស់ជំនួយទ្វេភាគីបានទៅទំនាក់ទំនងផ្ទាល់ជាមួយរាជធានី ខេត្ត ដើម្បីកត់ត្រាចូលទៅក្នុងគំរោងថវិការបស់រាជធានី ខេត្ត ។ ទន្ទឹមនឹងនេះ ក៏ត្រូវយកចិត្តទុកដាក់ផងដែរក្នុងការកត់ត្រារាល់ចំណាយថវិកាបដិភាគជាប្រាក់រៀល ដែលត្រូវអនុវត្តជាមួយគំរោង ដោយហិរញ្ញប្បទានពីបរទេសផ្ទាល់ ។

18. ចំណាយនេះ ជាចំណាយកសាងថ្មីដែលមានទំហំទឹកប្រាក់ច្រើន ដូចជា ដីធ្លី អាគារ រៀបចំតុបតែងអាគារ និងសំណង់ផ្សេងៗទៀត ។

## III. សរុបគំរោងចំណូល ចំណាយ :

19. ឆ្នាំ ២០១០ គឺជាឆ្នាំទី ២ របស់រាជរដ្ឋាភិបាលអាណត្តិទី ៤ រាជរដ្ឋាភិបាលនៅតែយល់ឃើញថាការបន្តរក្សា អោយបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ជាមធ្យមពី ៦ ទៅ ៧ ភាគរយប្រកបដោយចីរភាព និងបន្តរក្សាបាននូវស្ថេរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ចនៅតែជាមូលដ្ឋានគន្លឹះ និងចាំបាច់បំផុតក្នុងការឈានទៅសំរេចបាននូវគោលដៅចុងក្រោយរបស់រាជរដ្ឋាភិបាលគឺ **ការកាត់បន្ថយភាពក្រីក្រ ភាពសុខដុមរមនា និងសុភមង្គល របស់ប្រជាជន** ។ ដើម្បីសំរេចបានតាមគោលដៅខាងលើរាជរដ្ឋាភិបាលនឹងត្រូវបន្តអនុវត្ត **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ២០០៦_២០១០ ដែលផ្អែកលើ **យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និង**

**ប្រសិទ្ធភាព** ។ រាជរដ្ឋាភិបាល នឹងត្រូវបន្តជំរុញការអភិវឌ្ឍតាមវិស័យ ដូចជា ការអភិវឌ្ឍវិស័យសេដ្ឋកិច្ចដែលត្រូវផ្តោតលើកសិកម្ម កសិឧស្សាហកម្ម និងការអភិវឌ្ឍជនបទ ការអភិវឌ្ឍវិស័យសង្គមកិច្ច ដែលត្រូវផ្តោតទៅលើការអប់រំ សុខាភិបាល និងការកសាងធនធានមនុស្ស ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដែលត្រូវផ្តោតលើផ្លូវ ថ្នល់ ស្ពាន ប្រព័ន្ធធារាសាស្ត្រ និងការអភិវឌ្ឍវិស័យឯកជន ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាល នឹងត្រូវបន្តជំរុញការការអនុវត្តបណ្តាកម្មវិធីកែទំរង់លើគ្រប់វិស័យ អោយកាន់តែស៊ីជំរៅដូចជា ការកែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ការកែទំរង់រដ្ឋបាលសាធារណៈនិងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ការកែទំរង់កងកម្លាំងប្រដាប់អាវុធ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដើម្បីសំរេចបាននូវការគ្រប់គ្រងប្រកបដោយអភិបាលកិច្ចល្អនិងការផ្តល់សេវាសាធារណៈប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់ ។

គំរោងចំណូល ចំណាយថវិការបស់រាជធានី ខេត្ត នីមួយៗដែលបានគិតគូរ រួមមានទាំងការធានាចំណាយដែលមិនទាន់បានធ្វើការទូទាត់ និងចំណូលដែលមិនទាន់បានប្រមូលអស់នៃការគ្រប់គ្រងក្នុងឆ្នាំមុន១ផង ។ គំរោងចំណូល ចំណាយនេះ ត្រូវរៀបចំអោយមានតុល្យភាពពិតប្រាកដ ដើម្បីរក្សាបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ។

20. ចំពោះគំរោងចំណាយចរន្តរាជធានី ខេត្ត ត្រូវភ្ជាប់មកជាមួយនូវគំរោងបែងចែកលំអិត តាមក្រុង ស្រុក ខណ្ឌនីមួយៗ ដូចដែលមានគំរូតារាងឧបសម្ព័ន្ធ ២ " ខ " ដែលភ្ជាប់នឹងសារាចរណែនាំនេះ ។

21. ដោយឡែកនៅឆ្នាំ ២០១០ ខាងមុខនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបន្តអនុវត្តកម្មវិធីកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស ពង្រឹងនូវគោលដៅជំហានទី ១ គឺភាពជឿទុកចិត្តបាននៃថវិកាតាមរយៈការបន្តជំរុញការកាត់បន្ថយនីតិវិធីចំណាយ ការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ការបង្កើនភាពគ្រប់ជ្រុងជ្រោយ និងធ្វើសមាហរណកម្មថវិកា ដើម្បីធានាអោយការបើកផ្តល់ថវិកាបានទាន់ពេលវេលា ។ ពង្រឹងការកសាងក្របខ័ណ្ឌគោលនយោបាយចំណូលដើម្បីរក្សាស្ថេរភាព និងនិរន្តរភាពចំណូល ក្នុងការឈានចូលនូវការអនុវត្តគោលដៅជំហានទី ២ ។ ទន្ទឹមនឹងនេះ បន្តជំរុញការរៀបចំផែនការសកម្មភាព និងបន្តអនុវត្តនូវបណ្តាសកម្មភាពការងារសំរាប់ឈានចូលនូវគោលដៅជំហានទី ៣ និងទី ៤ គឺការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ និង ការពង្រឹងការឆ្លើយតបនៃថវិកាទៅនឹងគោលនយោបាយដែលរួមមាន ការបន្តពង្រឹង និងកែលំអរការអនុវត្ត ប្លង់គណនេយ្យ និងមាតិថវិកាថ្មី ការបន្តពង្រឹងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកាតាមកម្មវិធី និងជំរុញការអនុវត្តច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដើម្បីអោយប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈថ្មីស្តែងឡើងជាសមិទ្ធិផល និងជាកំលាំងចលករក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

22. បន្តជម្រុញអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ពិសេសធានាពង្រឹងសមត្ថភាពរដ្ឋបាលបច្ចេកទេស និងហិរញ្ញវត្ថុ របស់ក្រុមប្រឹក្សាឃុំ សង្កាត់ សំរាប់ការអភិវឌ្ឍន៍មូលដ្ឋាន និងពង្រីកមូលដ្ឋាននៃការគ្រប់គ្រងហិរញ្ញវត្ថុតាមបែបវិសហមជ្ឈការ ពិសេសគឺដើម្បីបំរើអោយគោលការណ៍ "រដ្ឋបាលឯកភាព" ដូចមានកំណត់នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។ ក្នុងកម្មវិធីនេះ ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំ និងអនុវត្តផែនការបង្កើនប្រសិទ្ធភាពនៃការផ្ទេរ និងការផ្តល់ថវិកាជូនមូលនិធិ ឃុំ សង្កាត់ រួមមានទាំងលទ្ធភាពនៃការពង្រីកការប្រើប្រាស់ប្រព័ន្ធធនាគារផងដែរ ។ លើសពីនេះទៀត ក្រសួងសេដ្ឋកិច្ច និង

ហិរញ្ញវត្ថុ ត្រូវបន្តសិក្សាដើម្បីរៀបចំច្បាប់ស្ដីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋាននានាសំរាប់អនុវត្តប្រព័ន្ធហិរញ្ញវត្ថុនិងថវិការបស់រដ្ឋបាលនៅថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ នាពេលខាងមុខនេះ ។

23. បង្កើនមូលនិធិថវិកាឃុំ សង្កាត់ ឆ្នាំ ២០១០ ដល់ ២.៨០% នៃចំណូលចរន្តថវិការដ្ឋឆ្នាំ ២០០៩ ដែលបានអនុម័តដោយច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩ និងស្របតាមអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៧ ស្ដីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិ ឃុំ សង្កាត់ ។

24. ពេលទទួលបានសារាចរណែនាំរាជធានី ខេត្ត ត្រូវរៀបចំជាបន្ទាន់នូវគំរោងចំណូល ចំណាយថវិការបស់ខ្លួនសំរាប់ការគ្រប់គ្រងឆ្នាំ ២០១០ ទៅតាមឧបសម្ព័ន្ធតារាងគំរូ (ឧបសម្ព័ន្ធទី ១ ឧបសម្ព័នទី ២ និងតារាងលេខ ១ ដល់លេខ៧ ) ដែលភ្ជាប់មកជាមួយនេះ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន) ចំនួនពីរច្បាប់ យ៉ាងយូរបំផុតត្រឹមថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៩ ដើម្បីមានពេលវេលាគ្រប់គ្រាន់សំរាប់ពិភាក្សាកំរិតជំនាញ និងបូកសរុបសំរាប់ពិភាក្សាចាប់ពីថ្ងៃទី ០១ ដល់ ៣១ ខែ សីហា ឆ្នាំ ២០០៩ ។ តួលេខគំរោងចំណូល ចំណាយថវិកាត្រូវសរសេរជាលេខអន្តរជាតិ (1.2.3) ហើយឯកត្តាទាបបំផុតគិតត្រឹម 0.1លានរៀល ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹមជឿជាក់យ៉ាងមុតមាំថា អភិបាលរាជធានី ខេត្តទាំងអស់នឹងខិតខំយកចិត្តទុកដាក់ចាត់ចែងអនុវត្តតាមខ្លឹមសារនៃសារាចរនេះ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៩

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**កន្លែងទទួល :**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
  (ដើម្បីជូនជ្រាប)
- គ្រប់សាលារាជធានី ខេត្ត
- គ្រប់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត
  (ដើម្បីមុខការ)
- ឯកសារ

៧៤